ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៦/១៨ - ហ្វីស ហ្គាវ័ន្ត អ៊ីតែរីល (ខេមបូឌា) ខូអិលធីឌី
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់៖ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ុន គឹមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហ្វីស ហ្គាវ័ន្ត អ៊ីតែរីល (ខេមបូឌា) ខូអិលធីឌី**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ២ ភូមិព្រែកតាឡុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ម៉ៃ និមិត្ត ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖ **អវត្តមាន**

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ្វីស ហ្គាវ័ន្ត អ៊ីតែរីល (ខេមបូឌា) ខូអិលធីឌី**

- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ហ្វីស ហ្គាវ័ន្ត អ៊ីតែរីល (ខេមបូឌា) ខូ អិលធីឌី**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ២ ភូមិព្រែកតាឡុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៧ ៧៧៧ ៨១៩ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

| | |
|---|---|
| ១- លោក ស៊ាង យ៉ូត | ប្រធានកម្មវិធីដោះស្រាយវិវាទនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោក ឃឹម មករា | ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ហ្វឹស ហ្គារ័ន្ត អីភែរីល (ខេមបូឌា) ខូ អិលធីឌី |
| ៣- លោក សៅ ពិសី | បុគ្គលិកសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៤- លោក ផាន់ សាវ៉ុន | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ហ្វឹស ហ្គារ័ន្ត អីភែរីល (ខេមបូឌា) ខូ អិលធីឌី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួល ក្នុងមួយខែ ពីរដង។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនរៀបចំបោះឆ្នោតតំណាងជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិថ្មី។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនសុំទុកពេលពិភាក្សាជាមួយថៅកែសិន។

៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនសងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ បង្គ្រប់ ១០០ ភាគរយ ក្នុងអំឡុងពេលព្យួរការងារកាលពី

- នៅថ្ងៃទី២៤ ដល់ថ្ងៃ២៧ ខែមីនា ឆ្នាំ២០១៧ ព្យួរក្រុម ១ ចំនួន ២៤ នាក់ ក្រុម ៦ ចំនួន ២៥ នាក់ និងក្រុម ៨ ចំនួន ២១ នាក់។
- នៅថ្ងៃទី២៤, ២៥ ខែមីនា ឆ្នាំ២០១៧ ព្យួរក្រុម៩ ចំនួន ១៤ នាក់ ក្រុម២ ចំនួន ៤ នាក់។
- នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ព្យួរក្រុមវេចខ្ចប់ ចំនួន ០៥ នាក់ និងក្រុមផ្សេងៗទៀត។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនសុំទុកពេលពិភាក្សាសិន។

៤- កម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតព្យួរការងាររយៈពេលពីរខែ ពេលគាត់មានធុរៈ។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ។

៥- កម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកសងប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ អំឡុងពេលកម្មករនិយោជិតធ្វើកូដកម្មនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩

សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២០៨ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ (អាណត្តិទី១៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្វ៊ីស ហ្គាវ័ន្ត អីភែរីល (ខេមបូឌា) ខូអិលធីឌី លេខ ៩៨៦ ក.ប/អក/វក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ ។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ១២រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ១៤ និង ០០ នាទី រសៀល ។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ការិយាល័យវិវាទការងារទី១ នៃនាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ១៤០/១៧ ស.ប.ក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនកែលម្អលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ។ ក្រោយពីទទួលបានបណ្តឹងនេះ ការិយាល័យវិវាទការងារទី១ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងាររួមនេះ និងបានធ្វើការផ្សះផ្សានៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ លើចំណុចវិវាទ ចំនួន ១១ ចំណុច ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នា ចំនួន ៥ ចំណុច ។ ចំណុចមិនសះជា ចំនួន ៥ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមរយៈលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៨ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ្វ៊ីស ហ្គាវ័ន្ត អីភែរីល (ខេមបូឌា) ខូអិលធីឌី លេខ ៩៨៦ ក.ប/អក/វក ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៨ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨ ។ ក្រុមអាជ្ញាកណ្តាលនៃសំណុំរឿងនេះបានទទួលព័ត៌មានតាមរយៈទូរសព្ទពីភាគីនិយោជកថា នៅក្នុងក្រុមហ៊ុន ហ្វ៊ីស ហ្គាវ័ន្ត អីភែរីល (ខេមបូឌា) ខូអិលធីឌី កំពុងមានកូដកម្ម ហើយកម្មករនិយោជិតបានយកសោរទៅចាក់នៅខ្លោងទ្វារធំរបស់ក្រុមហ៊ុន ធ្វើឱ្យនិយោជកមិនអាចចូលទៅក្នុងក្រុមហ៊ុនបាន ។ ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានផ្តល់ព័ត៌មានថា ពួកគាត់កំពុងធ្វើកូដកម្មទាមទារឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១៧ ដែលនិយោជកមិនបានបើកឱ្យ រីឯការទាមទាររបស់កម្មករនិយោជិតនៅក្នុងសំណុំរឿងលេខ ០០៦/១៨ នេះ មិនមានពាក់ព័ន្ធនឹងកូដកម្មនេះឡើយ ។

ARBITRATION COUNCIL

ក្រោយទទួលបានព័ត៌មានទាំងនេះ និងបន្ទាប់ពីក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងសាកសួរព័ត៌មានបន្ថែមទាក់ទងនឹងកូដកម្ម នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីកម្មករនិយោជិត មានវត្តមាន តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដោយឡែក ភាគីនិយោជកមិនបានចូលរួមតាមការអញ្ជើញនោះទេ ភាគីនិយោជកបានស្នើសុំតាមរយៈទូរសព្ទមកកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យពន្យារពេលសវនាការ ដោយបញ្ជាក់ពីមូលហេតុថា នាយកក្រុមហ៊ុនកំពុងរវល់ដោះស្រាយបញ្ហាជាមួយកម្មករនិយោជិតនៅក្រុមហ៊ុនរបស់គាត់មួយផ្សេងទៀត ហើយក៏មិនមានអ្នកតំណាងនាយកក្រុមហ៊ុនមកចូលរួមសវនាការបាន ដោយសារតែមិនមានលិខិតផ្ទេរសិទ្ធិពីនាយកក្រុមហ៊ុន ពីព្រោះ ឯកសារផ្ទេរសិទ្ធិទាំងនោះស្ថិតនៅក្នុងបន្ទប់ ដែលត្រូវបានចាក់សោរជាប់ដោយភាគីកម្មករនិយោជិត។ ភាគីនិយោជកក៏បានបញ្ជាក់ដែរថា អគារផលិតកម្មក៏ត្រូវបានចាក់សោរដោយភាគីកម្មករនិយោជិត។

មុននឹងសម្រេចថា ត្រូវបន្តធ្វើសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសាកសួរព័ត៌មានបន្ថែម ទៅកាន់ភាគីកម្មករនិយោជិតទាក់ទងនឹងបញ្ហាកូដកម្មជាមុនសិន។ ភាគីកម្មករនិយោជិតបានអះអាងថា ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ មក កម្មករនិយោជិតបានធ្វើកូដកម្មមែន ប៉ុន្តែការធ្វើកូដកម្មនោះ មិនពាក់ព័ន្ធនឹងការទាមទារនៅក្នុងសំណុំរឿងនេះទេ ហើយការធ្វើពាក្យបណ្តឹងទាក់ទងនឹងសំណុំរឿងនេះ បានធ្វើឡើងមុនពេលមានកូដកម្មកើតឡើងផងដែរ។ នៅពេលបច្ចុប្បន្ន ក៏មានកម្មករនិយោជិតមួយចំនួនទៅក្រុមហ៊ុន គឺពួកគាត់ដាក់វេនគ្នាយាម ដោយខ្លាចនិយោជកលួចដឹកម៉ាស៊ីនចេញ។ នៅពេលដែលកម្មករនិយោជិតទៅដល់ក្រុមហ៊ុន ពួកគាត់មិនអាចចូលទៅក្នុងអគារផលិតកម្មបានទេ ពីព្រោះ និយោជកបានចាក់សោរគ្រប់អគារផលិតកម្ម មិនឱ្យពួកគាត់ចូលធ្វើការបាន ពោលគឺមានតែក្លោងទ្វារធំ ដែលមិនបានចាក់សោរ។ សព្វថ្ងៃនេះ មានតែសន្តិសុខប៉ុណ្ណោះ ដែលអាចនៅធ្វើការបាន ហើយសូម្បីតែបុគ្គលិកការិយាល័យ ក៏មិនឃើញមកធ្វើការដែរ។

យោងតាមព័ត៌មានដែលទទួលបានពីភាគីទាំងពីរខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានភាពស៊ីសង្វាក់គ្នាត្រង់ចំណុចដែលថា តើនរណាជាអ្នកចាក់សោរអគារផលិតកម្ម។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចធ្វើការស៊ើបអង្កេត ដោយចុះផ្ទាល់ទៅកាន់ក្រុមហ៊ុននៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៩ ព្រឹក។ ដោយហេតុថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានបំណងស្វែងរកនូវព័ត៌មានជាក់លាក់ និងពិតប្រាកដ ហេតុនេះការស៊ើបអង្កេតមិនត្រូវបានផ្តល់ដំណឹងជាមុន ជូនភាគីទាំងពីរនោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការសាកសួរទៅកាន់កម្មករនិយោជិត និងសន្តិសុខមួយចំនួនដែលនៅក្នុងក្រុមហ៊ុន។ សន្តិសុខបានបញ្ជាក់ថា សោរទ្វារដែលចាក់នោះ ជារបស់និយោជក ព្រមជាមួយគ្នានោះ កម្មករនិយោជិតឈ្មោះ សាត សំណាង ដែលជាប្រតិភូបុគ្គលិក និងជាលេខាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន ហ៊ីស ហ្គាវ័ន្ត អ៊ីភែរីល (ខេមបូឌា) ខូអិលធីឌី បានអះអាងដូចគ្នាដែរថា និយោជកបានចាក់សោរអគារផលិតកម្ម មិនឱ្យកម្មករនិយោជិតចូលធ្វើការបានទេ។ ក្នុងអំឡុងពេលសាកសួរនោះ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានទូរសព្ទទៅកាន់ភាគីកម្មករនិយោជិត និង

THE ARBITRATION COUNCIL

និយោជក ដើម្បីផ្តល់ជាដំណឹងអំពីការចុះស៊ើបអង្កេតរបស់ខ្លួន ព្រមទាំងអញ្ជើញភាគីទាំងពីរឱ្យមកក្រុមហ៊ុនផងដែរ ប៉ុន្តែ ភាគីទាំងពីរបានឆ្លើយតបថា មិនអាចអញ្ជើញមកបានទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមក្រុមហ៊ុន ហ៊្វឹស ហ្គារ័ន្ត អ៊ីភែរីល (ខេមបូឌា) ខូអិលធីឌី លេខ ០០៥/១៨ កប/អក/វក/លបវ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ ដោយនាយកដ្ឋានវិវាទការងារ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ហ៊្វឹស ហ្គារ័ន្ត អ៊ីភែរីល (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ហ៊្វឹស ហ្គារ័ន្ត អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី លេខចុះបញ្ជី ១១២១៧០២៩៧ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧។

៤- លិខិតលេខ ៣៣៣ កប/វក ចុះថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបញ្ជាក់ថា អង្គការវិជ្ជាជីវៈសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ហ៊្វឹស ហ្គារ័ន្ត អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី ត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេលលក្ខណ:ច្បាប់ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

៥- លក្ខន្តិកៈសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ហ៊្វឹស ហ្គារ័ន្ត អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី បានចុះបញ្ជីលេខ ១១២១៧០២៩៧ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ដោយប្រធាននាយកដ្ឋានវិវាទការងារ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ៊្វឹស ហ្គារ័ន្ត អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី លេខ ៩៨៦ ក.ប/អក/វក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ៊្វឹស ហ្គារ័ន្ត អ៊ីភែរីល (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមក្រុមហ៊ុន ហ្វីស ហ្គារ៉ិន្ត អ៊ីភែរីល (ខេមបូឌា) ខូអិលធីឌី លេខ ០០៥/១៨ កប/អក/វក/លបវ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ ដោយនាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៣៩ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៤០ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៦ រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨។

**អង្គហេតុ ៖**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា ៖ *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"*។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការនេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៩/០៦-សាង វ៉, លេខ ៣៥/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩ & ១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាណូ, លេខ ១០៤/១៣-សាប្រ៊ីណា (ខេមបូឌា), លេខ ៣២២/១៤-ជីម លី (ខេមបូឌា) ភីធីអ៊ី អិលធីឌី, ០៧១/១៥-អ៊ឹម វ៉េ កាត់ដេរ អន្តរជាតិ សាខាកំពង់ឆ្នាំង និងលេខ ០២១/១៦-ស្តារឡៃថ៍ អ៊ីភែរីល មេនូហ្វេកធើរីង)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ខណៈពេលដែលសំណុំរឿងវិវាទបញ្ជូនមកដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល កម្មករនិយោជិតកំពុងតែធ្វើកូដកម្ម ប៉ុន្តែ រហូតដល់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួល

ព័ត៌មានមិនស៊ីសង្វាក់គ្នា ពាក់ព័ន្ធនឹងការចាក់សោរអគារផលិតកម្ម ដោយភាគីនិយោជកអះអាងថា កម្មករនិយោជិតជាអ្នកចាក់សោរ ប៉ុន្តែ កម្មករនិយោជិតបញ្ជាក់ថា និយោជកជាអ្នកចាក់សោរនោះ។

ប្រការ ២៤ នៃប្រកាសលេខ ០៩៩ ខាងលើ ដដែល ចែងថា ៖ *“ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងការស៊ើបពត៌មានអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពសង្គមនៃកម្មករនិយោជិតដែលពាក់ព័ន្ធនៅក្នុងវិវាទ។ ក្រុមនេះអាចដឹកនាំការស៊ើបអង្កេតណាមួយ ដែលមានការទាក់ទងនឹងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងអាចតម្រូវអោយភាគីប្រគល់ជូននូវឯកសារ ឬ ពត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាលដែលអាចមានប្រយោជន៍ក្នុងការបំពេញបេសកកម្មរបស់ខ្លួន។ ក្រុមអាជ្ញាកណ្តាលនេះ អាចសុំអោយអ្នកជំនាញការជួយបានទៀតផង។”*

តាមរយៈប្រការ ២៤ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដឹកនាំការស៊ើបអង្កេតដើម្បីស្វែងរកព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុន ឬអង្គការវិជ្ជាជីវៈផ្សេងៗដើម្បីធ្វើជាមូលដ្ឋានក្នុងការពិចារណាសំណុំរឿង ឬការទាមទារនៅក្នុងសំណុំរឿងដែលខ្លួនត្រូវសម្រេចសេចក្តី។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចធ្វើការស៊ើបអង្កេត ដោយចុះផ្ទាល់ទៅកាន់ក្រុមហ៊ុននៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៩ ព្រឹក។ តាមរយៈការស៊ើបអង្កេតនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានពីសន្តិសុខដែលយាមក្រុមហ៊ុនថា និយោជកជាអ្នកចាក់សោរគ្រប់អគារផលិតកម្មមិនឱ្យកម្មករនិយោជិតចូលធ្វើការងារបាន។

កថាខណ្ឌទី២ មាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *“ឡុកអៅ គឺជាការបិទសហគ្រាស ឬគ្រឹះស្ថានទាំងមូល ឬមួយផ្នែកដោយនិយោជក ក្នុងឱកាសដែលមានវិវាទការងារ។”* ។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គិតមកត្រឹមថ្ងៃដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចុះទៅស៊ើបអង្កេត និយោជកបានបិទក្រុមហ៊ុនរបស់ខ្លួនទាំងមូល តាមរយៈការចាក់សោរគ្រប់អគារផលិតកម្មមិនឱ្យកម្មករនិយោជិតចូលធ្វើការងារបាន ហើយការបិទនេះ ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលកម្មករនិយោជិត និងនិយោជកកំពុងមានសំណុំរឿងវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ ដូចនេះ យោងតាមកថាខណ្ឌទី២ មាត្រា ៣១៨ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សកម្មភាពរបស់និយោជកជា ឡុកអៅ។

ហេតុនេះ យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចបន្តនីតិវិធី និងដំណើរការសវនាការបានទេ គឺក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០០៦/១៨-ហ្វឹស ហ្គាវ៉ិន្ត អឹកែរីល (ខេមបូឌា) ខូអិលធីឌី។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ---------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ស៊ុន គឹមស៊ាន**

ហត្ថលេខា ៖ ---------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ---------------------------------

THE ARBITRATION COUNCIL